កិច្ចប្រជុំជាន់ខ្ពស់ស្តីពី

" ការកាត់បន្ថយការរើសអើងនិង មាក់ងាយ ដើម្បីពង្រឹងការអនុវត្ត

បទអន្តរាគមន៍ក្នុងការបង្ការមេរោគអេដស៍ និងជំងឺអេដស៍

ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស

និងក្រុមស្រីស្រស់នៅកម្ពុជា "

*ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣*

*សណ្ឋាគារៈ សាន់វេភ្នំពេញ*

*សូមគោរពអង្គពីធីទាំងមូល*

***ឯ.ឧ អៀង មូលី ទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍***

***ឯ.ឧ វេជ្ជ. តែង គន្ធី អគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់***

***លោកជំទាង ម៉ក់ វណ្ណស៊ីថា អភិបាលរងរាជធានីភ្នំពេញ និងជាប្រធានគណៈកម្មាការអេដស៍រាជធានីភ្នំពេញ***

***លោក ជួប សុខចំរើន តំណាងសម្ព័ន្ធអង្គការ Flagship***

***ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្រុមអ្នកបុរសស្រឡាញ់បុរស ក្រុមស្រីស្រស់ និងអង្គពិធីទាំងមូលជាទីមេត្រី !***

ថ្ងៃនេះខ្ញុំមានសេចក្តីរីករាយជាខ្លាំងដែលបានចូលរួមក្នុងកិច្ចប្រជុំ និងមានឱកាសមានចំណាប់អារម្មណ៍ ក្នុងនាមជាតំណាងឱ្យអង្គការ**អង្គការសេវាសង្គមសុខភាពបុរស** (MHSS) ក្នុងកិច្ចប្រជុំស្តីពី "**ការកាត់បន្ថយការរើសអើង និងមាក់ងាយ ដើម្បីពង្រឹងការអនុវត្តបទអន្តរាគមន៍ក្នុងការបង្ការមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់នៅកម្ពុជា** តាមរយៈកិច្ចសហការណ៍រៀបចំដោយ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (NAA) និងអង្គការសេវាសង្គមសុខភាពបុរស (MHSS) ក្រោមជំនួយថវិកាពីប្រជាពលរដ្ឋសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍអន្តរជាតិ ហៅកាត់ថា USAID តាមរយៈការគាំទ្របច្ចេកទេសពី សម្ពន្ធ័ Flagship ( KHANA,FHI360 and PSI/PSK) ដ៏មានសារៈសំខាន់នាពេលព្រឹកនេះក្នុងគោលបំណង កាត់បន្ថយការរើសអើង និងការម៉ាក់ងាយលើក្រុមបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់ និងពង្រឹងការគាំទ្រ តាមរយៈកិច្ចសហប្រតិ

បត្តិការណ៍ពីស្ថាប័នពាក់ព័ន្ធ ទៅលើបទអន្តរាគមន៍ និងកម្មវិធីបង្ការ ថែទាំ និងគាំទ្រមេរោគអេដស៍ ជំងឺអេដស៍ក្នុងចំណោមបុរសស្រឡាញ់បុរស និងក្រុមស្រី ស្រស់នៅក្នុងប្រទេសកម្ពុជា។

ជាការពិតណាស់មេរោគអេដស៍ និងជំងឺអេដស៍ជំងឺអេដស៍ នូវតែជាបញ្ហាដ៏ធំមួយក្នុងប្រទេសកម្ពុជាដែលបណ្តាលឱ្យប្រជាជនទាំងមូល ប្រឈមនឹងគ្រោះថ្នាក់ដោយសារជំងឺដ៏ស្មៀមស្ងាត់មួយនេះ។ តាមរយៈការអនុវត្តការងារកន្លងទៅ យើងសង្កេតឃើញថានៅកម្ពុជាក្រុមដែលងាយរងគ្រោះថ្នាក់ ដោយសារជំងឺអេដស៍មាន ៣ ក្រុមសំខាន់ ដែលរួមមាន ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស ក្រុមអ្នកបម្រើការនៅកន្លែងកម្សាន្តសប្បាយ និងអ្នកប្រើប្រាស់គ្រឿងញៀន។ ខ្ញុំសូមធ្វើគូសបញ្ជាក់ផងដែរថា តាមរយៈការអង្កេតស្រាវជ្រាវរបស់អង្គការ FHI360 ក្នុងឆ្នាំ ២០១០ អត្រាផ្ទុកមេរោគអេដស៍ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស មានចំនួន ២.២ % ដែលតួរលេខនេះ នូវតែមានកម្រិតខ្ពស់នៅឡើយបើប្រៀបធៀបប្រទេសក្នុងតំបន់។

***គណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូលជាទីមេត្រី!***

ឆ្លៀតក្នុងឱកាសដ៏មានសារៈសំខាន់នេះ ខ្ញុំសូមធ្វើការសង្ខេបជូនដោយខ្លីនូវសកម្មភាពរបស់អង្គការសេវាសង្គមសុខភាពបុរស (MHSS) ក្នុងការចូលរួមចំណែកទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់នៅកម្ពុជា។ បច្ចុប្បន្ននេះ អង្គការសេវាសង្គមសុខភាពបុរស (MHSS) បានកំពុងអនុវត្តសកម្មភាពក្នុងខេត្តចំនួន ៩ រាជធានី មានប្រមានបុគ្គលិក ៣០ នាក់ និងក្រុមគោលដៅដែលជាបុរសស្រឡាញ់បុរស និងស្រីស្រស់នៅប្រមាណជិត ៨០០០នាក់ ហើយសកម្មភាពសំខាន់ផ្តោតលើបទអន្តរាគមន៍បង្ការ ថែទាំ និងគាំទ្រលើបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ជំងឺអេដស៍។ ឆ្លងតាមរយៈការអនុវត្តការងារកន្លងទៅយើងសង្កេតឃើញថាបញ្ហាប្រឈមមួយចំនួនដែលបានកើតឡើងដូចជា ការរើសអើង ការម៉ាក់ងាយ ខ្វះការគាំទ្រនិងសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា។

ក្នុងកិច្ចប្រជុំពេលនេះ ខ្ញុំមានសង្ឃឹមយ៉ាងម៉ុតមាំថា រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធនានា ជាពិសេសអាជ្ញាធរ និងប៉ូលិសមូលដ្ឋាន និងបន្តចូលរួមឱ្យកាន់តែខ្លាំងខ្លាជាងដ ដើម្បីឱ្យការអនុវត្តការងារកាន់តែមានប្រសិទ្ធភាពខ្ពស់។

ឆ្លៀតក្នុងឧកាសដ៏មហាវិសេសវិសាលនេះ ខ្ញុំសំដែងនូវការស្វាគមន៍ និងការកោតសរសើរជូនចំពោះ ឯ.ឧ លោកជំទាវ ដែលបានលះបង់កំលាងកាយចិត្ត និងប្រាជ្ញាស្មារតីចូលរួមចំនែកដឹកនាំគ្រប់គ្រង និងចូលរួមឆ្លើយតបទំលំទូលាយ និងពហុវិស័យប្រយុទ្ធនិងជំងឺអេដស៍នៅគ្រប់លំដាប់ថ្នាក់ រហូតទទួលបានជោគជ័យជាបន្តរបន្ទាប់គួរជាទីមោទនៈនៅក្នុងឆ្នាំ២០១៣ និងសូមជូនពរឱ្យគណៈអធិបតី ឯកឧត្តម លោកជំទាវ លោកលោកស្រី និងអង្គពិធីទាំងមូលទទួលបានសេចក្តីសុខ សេចក្តីចំរើន និងសុខភាពមាំមួន។

សូមអគុណ!